ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សន្ទរកថា ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជា ប្រធានគណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំកម្ពុជា ថ្លែងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ របស់ក្រុមប្រជាជនរងផលប៉ះពាល់ ជាងគេ អ្នករស់នៅជាមួយជំងឺអេដស៍ របេង គ្រុនចាញ់ និងក្រុមអង្គការសាសនា

រៀបចំដោយគណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំកម្ពុជា

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥

សណ្ឋាគារភ្នំពេញ

- លោកស្រី Inga Oleksy មន្ត្រីសម្រួលទំនាក់ទំនងមូលនិធិសកលរបស់ USAID និងជា សហប្រធានគណៈកម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការសំរបសំរួលមូលនិធិសកល ប្រចាំកម្ពុជា
- គណៈអធិបតី ភ្ញៀវកិត្តិយស បងប្អូនតំណាងក្រុម ប្រជាពលរដ្ឋ រងការប៉ះពាល់ពី ជំងឺអេដស៍ របេង គ្រុនចាញ់ជាងគេ និងសមាជិកសមាជិការនៃកិច្ចប្រជុំទាំងអស់។

ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានចូលរួមស្វាគមន៍អ្នកទាំងអស់គ្នា និងបើកកិច្ចប្រជុំ ពិគ្រោះយោបល់នាព្រឹកនេះ ជាមួយការចូលរួមពីបងប្អូនជាតំណាង និង អ្នកសំរបសំរួលថ្នាក់ កណ្តាល នៃប្រជាជនដែលរងការប៉ះពាល់ជាងគេ និង អ្នកដែលរស់នៅជាមួយជំងឺទាំងបីគឺៈ ជំងឺ អេដស៍ របេង គ្រុនចាញ់។ ការចូលរួមយ៉ាងសកម្មនៃតំណាងរបស់បងប្អូននៅក្នុងដំណើរការ និង យន្តការនានា តាំងពីពាក់កណ្តាលឆ្នាំ២០១៤មក ត្រូវបានទទួលស្គាល់ជាវិជ្ជមានពីមូលនិធិសកល និង ពីគណៈកម្មការសំរបសំរួលមូលនិធិសកលប្រចាំកម្ពុជា។

ខ្ញុំដឹងថាអ្នកទាំងអស់គ្នាបានធ្វើដំណើរឆ្ងាយណាស់ដើម្បីចូលរួមនៅទីនេះ ដូចជាអ្នកដែល មកពីបន្ទាយមានជ័យ ប៉ោយប៉ែតជាដើម មកចូលរួមស្តាប់នូវបច្ចុប្បន្នភាពទាំងឡាយអំពីដំណើរការ

និងសេចក្តីសំរេចចិត្តដែលគណៈកម្មាធិការសំរបសំរួលមូលនិធិសកលបានធ្វើឡើង ជាពិសេស លទ្ធផលនៃការដាក់ឯកសារបង្ហាញទស្សនៈ (Concept note) របស់កម្ពុជា ទៅមូលនិធិ សកល សំរាប់គំរោងកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺ អេដស៍ របេង គ្រុនចាញ់ និងគំរោងកម្មវិធីពង្រឹង ប្រព័ន្ធសុខាភិបាល ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណជូនចំពោះលោក លោកស្រី ទាំងអស់ ដែលបានចូលរួមក្នុងក្រុមជជែកពិភាក្សានិងកិច្ចប្រជុំសន្ទនាកំរិតជាតិ ក្នុងមួយរយៈនេះ ដើម្បីរួមចំណែកចងក្រងខ្លឹមសារនៃឯកសារបង្ហាញទស្សនៈ ដែលត្រូវបានដាក់ជូនទៅស្នាក់ការ កណ្តាលរបស់មូលនិធិសកល ដើម្បីស្នើសុំមូលនិធិសំរាប់គំរោងប្រយុទ្ធនឹងជំងឺ អេដស៍ របេង គ្រុនចាញ់ និងគំរោងពង្រឹងប្រព័ន្ធសុខាភិបាល ។ ជាមួយការចូលរួមចំណែក និង ពាក់ព័ន្ធរបស់បង ប្អូនយើងសង្ឃឹមថា បើទោះជាការផ្តល់មូលនិធិត្រូវបានកាត់បន្ថយក៏ដោយក៏កម្មវិធីជាតិនៅតែអាច សំរេចបានជោគជ័យនិងទទួលបាននូវលទ្ធផល កាន់តែទូលំទូលាយប្រកបដោយអាទិភាពតាម ការកំណត់និងត្រឹមត្រូវ ហើយកម្មវិធីជាតិបន្តកិច្ចខិតខំដោះស្រាយបញ្ហាដែលសហគមន៍បានលើក ឡើងដើម្បីអោយកាន់តែមានប្រសិទ្ធភាព និង ភាពប្រទាក់ក្រឡាគ្នាឡើង។

ខ្ញុំក៏បានដឹងដែរថា ព្រឹកនេះលេខាធិការដ្ឋានគណៈកម្មាធិការសំរបសំរួលមូលនិធិសកល ប្រចាំកម្ពុជា នឹងជំរាបយ៉ាងលំអិតជូនបងប្អូនទាំងអស់អំពីនៃស្ថានភាពលទ្ធផលរបស់ឯកសារ បង្ហាញទស្សនៈដែលបានដាក់ជូនទៅស្នាក់ការធំរបស់មូលនិធិសកលទីក្រុងហ្សឺណែវ ។ កម្មវិធី ជាតិយើង នឹងបង្ហាញជាលំអិតនូវសេវាកម្មផ្សេងៗដែលមានបម្រុងសំរាប់ផ្តល់ជូនអ្នកជំងឺស្ថិតក្នុង ស្ថានភាពសុខភាពគ្រប់កំរិត និងជួយពន្យល់បងប្អូនយល់នូវសេវាទាំងឡាយត្រូវបានផ្តល់ហិរញ្ញប្ប ទានអោយដំណើការដោយមូលនិធិសកល ។ ខ្ញុំសូមលើកទឹកចិត្ត អោយបងប្អូនយកចិត្តទុកដាក់ ត្រងត្រាប់ស្តាប់ និង លើកឡើងនូវសំនូរព្រមទាំងផ្តល់យោបល់ត្រឡប់ជូនអង្គប្រជុំ នូវបទពិសោធន៍ និងបញ្ហាប្រឈមដែលបងប្អូនបានជួបប្រទះនៅពេលទទួលបានសេវា ឬ គ្មានការងឿងឆ្ងល់ ព្រោះ ថានេះ ជាឱកាសមួយសំរាប់អោយសហគមន៍បន្តជួយអោយមានការរៀបចំចងក្រងគំរោងកម្មវិធី និង បន្តពង្រឹងគំរោងកម្មវិធីផ្សេងៗដើម្បីកាត់បន្ថយការឆ្លងមេរោគអេដស៍ របេង និង គ្រុនចាញ់។

គណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំកម្ពុជា ដែលជាអង្គភាពអភិបាលពហុ-ភាគី បានកៀងគរអោយម្ចាស់ជំនួយដៃគូអភិវឌ្ឍន៍នានា សង្គមស៊ីវិល ក្រុមប្រជាជន និងសហគមន៍ រងការប៉ះពាល់ជាងគេពីជំងឺអេដស៍ របេង គ្រុនចាញ់ ចូលរួមចំណែកក្នុងការសំរេចទិសដៅលុប បំបាត់ និង ប្រយុទ្ធនឹងជំងឺទាំងនេះ ។ យើងក៏រួមបញ្ចូលយ៉ាងសកម្មនូវការពង្រឹង សេវាកម្មផ្តល់ជូន មាតានិងទារក ធានាការទទួលប្រើប្រាស់ឈាមដោយសុវត្ថិភាពសំរាប់ទាំងអស់គ្នា ។ ក្នុងនាមជា

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមជំរាបជូនថា យើងបានស្នើសុំនិងបានទទួលបាននូវការសន្យាការចូលរួមចំណែកបដិភាគជាមួយការផ្តល់ហិរញ្ញប្បទាន របស់មូលនិធិសកលប្រយុទ្ធនឹងជំងឺទាំងបី ហើយយើងសង្ឃឹមថាការចូលរួមបដិភាគនេះ និងបន្តកើនឡើងនៅឆ្នាំបន្តបន្ទាប់។

ព្រឹកនេះ បងប្អូននឹងមានពេលជជែកក្នុងក្រុមតំណាងតំបន់របស់បងប្អូន តើបងប្អូនអាចបន្តភាពជាតំណាងអោយមានប្រសិទ្ធភាពបានយ៉ាងដូចម្តេច? តើបងប្អូនអាចធ្វើអោយមាននិរន្តភាពនៃយន្តការប្រព័ន្ធផ្តល់ពត៌មានត្រឡប់វិញ ជាមួយគណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំប្រទេស និងកម្មវិធីជាតិក្នុងរយៈ៣ឬ៤ឆ្នាំនៃការអនុវត្តគំរោងកម្មវិធីបានយ៉ាងដូចម្តេច? ដំណើរការធ្វើអោយមានការចូលរួមពាក់ព័ន្ធសហការគ្នារបសសហគមន៍នេះ ជាតំរូវការចាំបាច់របស់ទំរង់ផ្តល់ហិរញ្ញប្បទានថ្មី (New funding model) ដែលកម្ពុជាបានអនុវត្តតាមយ៉ាងសកម្ម ហើយនឹងត្រូវបានវាយតំលៃក្នុងពេលដ៏ខ្លីខាងមុខ ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ សូមថ្លែងអំណរគុណដល់ដៃគូរទាំងអស់ អ្នកផ្តល់ទីប្រឹក្សាបច្ចេកទេស ជាពិសេស USAID កម្ពុជា ចំពោះជំនួយបច្ចេកទេសដែលបានជួយពង្រឹងក្រុមសហគមន៍រងការប៉ះពាល់ជាងគេ ក្រុមប្រជាពលរដ្ឋដែលរស់នៅជាមួយជំងឺទាំងនេះ ចំពោះក្រុមសាសនាដែលបានចូលរួមយ៉ាងសកម្មក្នុងគណៈកម្មាធិការសំរបសំរួលមូលនិធិសកលប្រចាំកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថា កិច្ចប្រជុំពិគ្រោះយោបល់នេះ នឹងជួយធ្វើអោយបងប្អូនយល់បានកាន់តែប្រសើរឡើងអំពីកម្មវិធីជាតិ និង តួនាទីរបស់បងប្អូនដែលជាតំណាងតំបន់នៅក្នុងដំណើរការប្រព្រឹត្តទៅនានារបស់ គណៈកម្មការសំរបសំរួលមូលនិធិសកលរបស់ប្រទេស ។ ខ្ញុំសង្ឃឹមថា បងប្អូនមានឱកាសស្គាល់គ្នា និងធ្វើការដោយរីករាយជាមួយគ្នាផង។

ខ្ញុំក៏សង្ឃឹមដែរថា លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់នេះនិងអាចអោយយើងធ្វើការរួមគ្នាបានយ៉ាងល្អ ដើម្បីសំរេចទិសដៅប្រយុទ្ធនឹងជំងឺទាំងបីសំរាប់រយៈពេល៣-៤ឆ្នាំខាងមុខនៅក្នុងប្រទេសរបស់យើង។

ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ពីពេលនេះតទៅ។

សូមអរគុណ!